លេខ ២៣ ចេញផ្សាយថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមេសា ឆ្នាំ២០២៣

និយ័តករបរធនបាលកិច្ច
គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា

## សិក្ខាសាលាស្តីពី "បរធនបាលកិច្ច៖ យន្តការប្រតិបត្តិការ និងវាក្យសព្ទគន្លឹះ"

នាព្រឹកថ្ងៃអង្គារ ១៤កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាស្តីពី "បរធន-បាលកិច្ច៖ យន្តការប្រតិបត្តិការ និងវាក្យសព្ទគន្លឹះ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច។

កម្មវិធីសិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោល-បំណងដើម្បីផ្តល់ព័ត៌មាននិងបញ្ជ្រាបការយល់ដឹងអំពីវិស័យបរធនបាលកិច្ចដល់អ្នកសារព័ត៌មានដែលបម្រើការងារនៅស្ថានីយ៍ទូរទស្សន៍ ស្ថានីយ៍វិទ្យុ និងអង្គភាពសារព័ត៌មាននានា និងនិស្សិតថ្នាក់ឧត្តមសិក្សា។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, អ្នកសារព័ត៌មាននិងអង្គភាពសារព័ត៌មាន, សាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា និងវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ។

## មាតិកា

❖ សិក្ខាសាលាស្តីពី "បរធនបាលកិច្ច÷ យន្តការប្រតិបត្តិការ និងវាក្យសព្ទគន្លឹះ" ទំព័រទី១
❖ កិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១៣ ទំព័រទី២
❖ ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ទំព័រទី៣
❖ កិច្ចប្រជុំវាយតម្លៃ និងបូកសរុបការងារអនុវត្តគម្រោងជាមួយក្រុមការងារបេសកកម្មធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) ទំព័រទី៣
❖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការវាយតម្លៃហានិភ័យថ្នាក់ជាតិពាក់ព័ន្ធនឹងការសម្អាតប្រាក់ក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី៣
❖ កម្មវិធីសប្បុរសធម៌ នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ ទំព័រទី៤
❖ ពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ទំព័រទី៤
❖ កម្មវិធីបិទការប្រកួតបាល់ទាត់ "ពានរង្វាន់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកទី៣ ឆ្នាំ២០២២" ទំព័រទី៥
❖ កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ទំព័រទី៥
❖ កិច្ចប្រជុំអន្តរនិយ័តករក្រោមឱវាទ **អ.ស.ហ.** ទំព័រទី៥
❖ ការសម្តែងការគួរសម និងសួរសុខទុក្ខ ឯកឧត្តមកិត្តិបរិរក្សបណ្ឌិត គាត ឈន់ ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ទំព័រទី៦
❖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែមីនា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែមេសា ឆ្នាំ២០២៣ ទំព័រទី៦
❖ កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយ អភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ទំព័រទី៦
❖ កម្មវិធីជជែកអំពីធុរកិច្ចលើកទី៤ ស្តីពី "ប្រតិបត្តិការបរធនបាលកិច្ចពាក់ព័ន្ធនឹងសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក នៅក្នុងប្រតិបត្តិការលក់-ទិញអចលនទ្រព្យ" ទំព័រទី៧
❖ កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ទំព័រទី៧
❖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ABA) និងពិធីទទួលស្គាល់ជាផ្លូវការសមាជិកភាពថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ទំព័រទី៧
❖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង **ន.ប.ធ.** ជាមួយ Cambodia Investment Review ទំព័រទី៨
❖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី៩
❖ កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការ ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ច" ទំព័រទី៩



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia ☎ (855) 23 237 888






រូបភាពសិក្ខាសាលាស្តីពី "បរធនបាលកិច្ចៈ យន្តការប្រតិបត្តិការ និងវាក្យសព្ទគន្លឹះ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១៣

នារសៀលថ្ងៃអង្គារ ១៤កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) អមដោយឯកឧត្តម **ឈី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** និងថ្នាក់ដឹកនាំនាយកដ្ឋាននៃ **ន.ប.ធ.** បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា** **អ.ស.ហ.** និងមានការចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ និងឯកឧត្តមអគ្គនាយក នៃនិយ័តករក្រោមឱវាទ **អ.ស.ហ.** ជាសមាជិក-សមាជិកា **អ.ស.ហ.** តាមរយៈប្រព័ន្ធសន្និសីទវីឌីអូពីចម្ងាយ (Zoom)។




រូបភាពកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

នាព្រឹកថ្ងៃពុធ ១៥កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារគណៈ-កម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា**។



រូបភាពពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា។

## កិច្ចប្រជុំវាយតម្លៃ និងបូកសរុបការងារអនុវត្តគម្រោងជាមួយក្រុមការងារបេសកកម្មធនាគារ អភិវឌ្ឍន៍អាស៊ី (ADB)

នារសៀលថ្ងៃពុធ ១៥កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១ បានរៀបចំកិច្ចប្រជុំវាយតម្លៃ និងបូកសរុបការងារអនុវត្តគម្រោងជាមួយក្រុមការងារបេសកកម្មធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជានាយកគម្រោង សមាសភាគទី១ ដោយមានការចូលរួមពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP សមាសភាគទី១, លោកបណ្ឌិត Takeshi Ueda ប្រធានក្រុមការងារ ADB ទទួលបន្ទុកគម្រោង ACSEP និងក្រុមការងារ, លោកបណ្ឌិត **សរ ចិត្រា** អគ្គលេខាធិការរងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជានាយកគម្រោង ACSEP សមាសភាគ២ និងក្រុមការងារ, តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និងតំណាងធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនាជាស្ថាប័នហិរញ្ញវត្ថុដៃគូ។



រូបភាពកិច្ចប្រជុំវាយតម្លៃ និងបូកសរុបការងារអនុវត្តគម្រោង ជាមួយក្រុមការងារបេសកកម្មធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការវាយតម្លៃហានិភ័យថ្នាក់ជាតិពាក់ព័ន្ធនឹងការសម្អាតប្រាក់ក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការវាយតម្លៃហានិភ័យថ្នាក់ជាតិពាក់ព័ន្ធនឹងការសម្អាតប្រាក់ក្នុងវិស័យបរធនបាលកិច្ច" នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ ឯកឧត្តមអគ្គនាយករង ប្រធាននាយដ្ឋាន និងសហការី បានអញ្ជើញដឹកនាំ និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការវាយតម្លៃហានិភ័យថ្នាក់ជាតិពាក់ព័ន្ធនឹងការសម្អាតប្រាក់ក្នុងវិស័យបរធនបាលកិច្ច" ក្នុងគោល-បំណងដើម្បីផ្សព្វផ្សាយ និងពន្យល់អំពីរបៀបនៃការវាយតម្លៃ

ខ្លួនឯងរបស់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ដល់បរធនបាល, ប្រតិបត្តិករបរធនបាល និងក្រុមហ៊ុនវាយតម្លៃ ដែលមានសមាសភាពអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច សរុបចំនួន ៧៩ រូប។



រូបភាពសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការវាយតម្លៃហានិភ័យថ្នាក់ជាតិពាក់ព័ន្ធនឹងការសម្អាតប្រាក់ក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**)។

## កម្មវិធីសប្បុរសធម៌ នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ

នាព្រឹកថ្ងៃសុក្រ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងលោកជំទាវរួមដំណើរដោយឯកឧត្តមអគ្គនាយករង លោក លោកស្រី ជាថ្នាក់ដឹកនាំបច្ចេកទេស និងសហការីនៃ **ន.ប.ធ.** បាននាំយកអំណោយជាសម្ភារៈប្រើប្រាស់ ព្រមទាំងរៀបចំជាអាហារសាមគ្គី ជូនដល់មជ្ឈមណ្ឌលទារក និងកុមារជាតិ ដែលជាមជ្ឈមណ្ឌលផ្តល់ការមើលថែទាំក្មេងៗ ដែលកំព្រា គ្មានអាណាព្យាបាល និងមានពិការភាព ទាំងការរស់នៅ ហូបចុក និងការមើលថែទាំជំងឺផ្សេងៗ ។

កម្មវិធីនេះមានការចូលរួមផងដែរ ពីតំណាងក្រុមហ៊ុនប្រតិបត្តិករ បុគ្គលពាក់ព័ន្ធផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច និងសប្បុរសជនពាក់ព័ន្ធ។



រូបភាពកម្មវិធីសប្បុរសធម៌ នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ កាលពីថ្ងៃទី៧ ខែមសា ឆ្នាំ២០២៣។

## ពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

នាព្រឹកថ្ងៃសៅរ៍ ៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសហការីបានអញ្ជើញចូលរួមពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ និងសូត្រមន្តលើករាសី សិរីសួស្តីឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) នៅទីស្តីការ **អ.ស.ហ.**។

ពិធីនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមប្រតិភូ ឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករក្រោមឱវាទ **អ.ស.ហ.**។



រូបភាពពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦។

## កម្មវិធីបិទការប្រកួតបាល់ទាត់ "ពានរង្វាន់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកទី៣ ឆ្នាំ២០២២"

នារសៀលថ្ងៃអាទិត្យ ៤រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង ថ្នាក់ដឹកនាំបច្ចេកទេស និងសហការីនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមកម្មវិធីបិទការប្រកួតបាល់ទាត់ "ពានរង្វាន់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកទី៣ ឆ្នាំ២០២២" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** នៅទីលានបាល់ទាត់នៃវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា។



រូបភាពកម្មវិធីបិទការប្រកួតបាល់ទាត់ "ពានរង្វាន់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកទី៣ ឆ្នាំ២០២២"។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

នាព្រឹកថ្ងៃចន្ទ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), ជាសមាជិកក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា និងជាអនុប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានដឹកនាំសហការី ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា តាមប្រព័ន្ធអនឡាញ Zoom។



រូបភាពកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា**។

## កិច្ចប្រជុំអន្តរនិយ័តករក្រោមឱវាទ អ.ស.ហ.

នារសៀលថ្ងៃចន្ទ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ**កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និង **លោក ហាយ សុវណ្ណ** ប្រធានស្ដីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានដឹកនាំសហការី ចូលរួមកិច្ចប្រជុំអន្តរនិយ័តករក្រោមឱវាទ **អ.ស.ហ.** អំពី "សេចក្តីព្រាងប្រកាសស្តីពីការបោះផ្សាយលក់ឯកតាមូលនិធិនៃគម្រោងវិនិយោគរួម" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។




រូបភាពកិច្ចប្រជុំអន្តរនិយ័តករក្រោមឱវាទ **អ.ស.ហ.** "ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ការសម្តែងការគួរសម និងសួរសុខទុក្ខ ឯកឧត្តមកិត្តិបរិក្សបណ្ឌិត គាត ឈន់ ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

នាព្រឹកថ្ងៃអង្គារ ៦រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង និងថ្នាក់ដឹកនាំបច្ចេកទេសបានចូលជួបសម្តែងការគួរសម និងសួរសុខទុក្ខ **ឯកឧត្តមកិត្តិបរិក្សបណ្ឌិត គាត ឈន់ ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ដែលនឹងឈានមកដល់ក្នុងពេលឆាប់ៗខាងមុខ។




រូបភាពការសម្តែងការគួរសម និងសួរសុខទុក្ខ ឯកឧត្តមកិត្តិបរិក្សបណ្ឌិត **គាត ឈន់** ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមីនា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែមេសា ឆ្នាំ២០២៣

នាព្រឹកថ្ងៃពុធ ៧រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមីនា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែមេសា ឆ្នាំ២០២៣ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ច ការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះមានការចូលរួមពីលោក/កញ្ញាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមីនា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។




រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែមីនា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែមេសា ឆ្នាំ២០២៣ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.)។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយ អភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

នាព្រឹកថ្ងៃពុធ ១៤រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាអនុប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានដឹកនាំសហការីចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយ អភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមការដឹកនាំសម្របសម្រួលរបស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច** និងធុរកិច្ចឌីជីថល តាមប្រព័ន្ធអនឡាញ Zoom។



រូបភាពកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយ អភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមការដឹកនាំសម្របសម្រួលរបស់ ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** អនុរដ្ឋលេខាធិការនៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កម្មវិធីជជែកអំពីធុរកិច្ចលើកទី៤ ស្តីពី "ប្រតិបត្តិការបរធន-បាលកិច្ចពាក់ព័ន្ធនឹងសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក នៅក្នុងប្រតិបត្តិការលក់-ទិញអចលនទ្រព្យ"

នារសៀលថ្ងៃសៅរ៍ ៣ កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាមួយ **ឯកឧត្តម គង់ ផល្លៈ** តំណាងឯកឧត្តម **បណ្ឌិត ហោ ម៉េង** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) ជាអធិបតីក្នុងកម្មវិធីជជែកអំពីធុរកិច្ចលើកទី៤ ស្តីពី "ប្រតិបត្តិការបរធនបាលកិច្ចពាក់ព័ន្ធនឹងសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) នៅក្នុងប្រតិបត្តិការលក់-ទិញអចលនទ្រព្យ" ជូនដល់ជូនដល់សាស្រ្តាចារ្យផ្នែកច្បាប់ និងនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ព្រមទាំងមេធាវី មន្ត្រីជំនាញផ្នែកច្បាប់ប្រចាំក្រុមហ៊ុន សហគ្រិន និងនិយោជិត នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។



រូបភាពកម្មវិធីជជែកអំពីធុរកិច្ចលើកទី៤ ស្តីពី "ប្រតិបត្តិការបរធនបាលកិច្ចពាក់ព័ន្ធនឹងសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក នៅក្នុងប្រតិបត្តិការលក់-ទិញអចលនទ្រព្យ"។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

នារសៀលថ្ងៃពុធ ៧កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាអនុប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានដឹកនាំសហការីចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមការដឹកនាំក្រោមដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខា-ធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងជាប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាពកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមការដឹកនាំក្រោមដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ABA) និងពិធីទទួលស្គាល់ជាផ្លូវការសមាជិកនាពថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)

នាព្រឹកថ្ងៃពុធ ៧កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញ

ចូលរួមក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់ គ្នារវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ABA) និងពិធីទទួលស្គាល់ជាផ្លូវការសមាជិកភាពថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) របស់វិស័យឯកជន ដែលត្រូវបានប្រព្រឹត្តទៅឡើងនៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពីតំណាងនៃស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។



រូបភាពពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ABA) និងពិធីទទួលស្គាល់ជាផ្លូវការសមាជិកភាពថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង ន.ប.ធ. ជាមួយ Cambodia Investment Review (CIR Media)

កាលពីរសៀលថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងលោក Harrison White ស្ថាបនិក និងនាយកប្រតិបត្តិ នៃក្រុមហ៊ុនសារព័ត៌មាន Cambodia Investment Review (CIR Media) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈនិងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។ គោលបំណងនៃការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ គឺដើម្បីបង្កើតកិច្ចសហការក្នុងភាពជាដៃគូជាមួយក្រុមហ៊ុនសារព័ត៌មាន CIR Media ក្នុងការបង្កើនការជំរុញ និងលើកកម្ពស់ការយល់ដឹងបន្ថែម ក៏ដូចជាដើម្បីបញ្ជ្រាបការយល់ដឹងអំពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា យន្តការបរធនបាលកិច្ច លក្ខខណ្ឌតម្រូវក្នុងការធ្វើប្រតិបត្តិការ បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងផលប្រយោជន៍ដែលអាចទាញយកចេញពីប្រតិបត្តិការបរធនបាលកិច្ច ការបង្កើតនិងបង្កើនទំនុកចិត្តតាមរយៈការបង្កើតបរធនបាលកិច្ចក្នុងធុរកិច្ចពាក់ព័ន្ធ និងក្នុងប្រតិបត្តិការរំហូរមូលធនទៅគ្រប់វិស័យក្នុងសេដ្ឋកិច្ចនិងសង្គមកម្ពុជា។ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពីតំណាងនៃនិយ័តករក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដៃគូសហប្រតិបត្តិការរបស់ **ន.ប.ធ.** ក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព រឺសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចផងដែរ។





រូបភាពពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង **ន.ប.ធ.** ជាមួយ Cambodia Investment Review។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តមបណ្ឌិត ម៉ក់ វ៉ាន់** ព្រឹទ្ធ-សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ,សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។




រូបភាពសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តមបណ្ឌិត ម៉ក់ វ៉ាន់** ព្រឹទ្ធសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។

## កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការ ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ច"

រសៀលថ្ងៃសុក្រ ៩ កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាមួយលោក Yee Con Long អភិបាល និងនាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន កាណា ត្រាស ឯ.ក ជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការ ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ច" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ក្រុមហ៊ុន កាណា ត្រាស ឯ.ក ដែលទទួលបានការអនុញ្ញាតពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម និងបរធន-បាលកិច្ចសង្គម។




រូបភាពកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការ ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ច"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888